អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៩

# សេចក្តីប្រកាសព័ត៌មាន
# ការតែងតាំងចៅក្រមថ្មីនៅ អ.វ.ត.ក

បន្ទាប់ពីបានទទួលការតែងតាំងពីអគ្គលេខាធិការអង្គការសហប្រជាជាតិ António Guterres និងបានទទួលការអនុម័តពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមរួចមក ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ប្រោសព្រះរាជទានតែងតាំងលោកស្រី Maureen HARDING CLARK (អៀរឡង់) ជាចៅក្រមអន្តរជាតិនៅអង្គជំនុំជម្រះតុលាការកំពូល នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

លោកស្រីចៅក្រម Clark ជំនួសលោកស្រីចៅក្រម Agnieszka KLONOWIECKA-MILART (ប៉ូឡូញ) ដែលបានលាឈប់ពីមុខតំណែងកាលពីចុងឆ្នាំ២០១៨។

លោកស្រីចៅក្រម Clark បានបំពេញការងារជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ក្នុងឆ្នាំ២០១៥។ លោកស្រីធ្លាប់បំពេញការងារជាចៅក្រម*បំពេញកិច្ច (ad litem)* នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY) ពីឆ្នាំ២០០១ ដល់ឆ្នាំ២០០៣ ហើយត្រូវបានបោះឆ្នោតជ្រើសរើសជាចៅក្រមនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ពីឆ្នាំ២០០៣ ដល់ឆ្នាំ២០០៦ ហើយមួយរយៈខ្លីក្រោយមក គាត់បានបំពេញការងារជាចៅក្រមនៅតុលាការជាន់ខ្ពស់របស់អៀរឡង់រហូតដល់ឆ្នាំ២០១៤។ មុនពេលលោកស្រីទទួលការតែងតាំងឲ្យកាន់មុខតំណែងក្នុងវិស័យតុលាការ លោកស្រីចៅក្រម Clark ប្រកបវិជ្ជាជីវៈមេធាវីពីឆ្នាំ១៩៧៥ និងទទួលបានការតែងតាំងជាមេធាវីជាន់ខ្ពស់នៅឆ្នាំ១៩៩១។ លោកស្រីក៏ធ្លាប់បានបំពេញការងារជាសមាជិកគណៈកម្មការសិទ្ធិមនុស្សអៀរឡង់, ជាប្រធាន និងសមាជិកតែម្នាក់នៃការស៊ើបអង្កេតទៅលើមន្ទីរពេទ្យ Lourdes, អ្នកវាយតម្លៃឯករាជ្យនៃគម្រោងទូទាត់ប្រាក់អតីតភាពសម្រាប់បុគ្គលិកផ្នែកវះកាត់ (Surgical Symphysiotomy Ex-gratia Payment Scheme) និងជាសាស្ត្រាចារ្យទស្សនកិច្ច (Judicial Visitor) នៃសាកលវិទ្យាល័យ Dublin (មហាវិទ្យាល័យ Trinity College)។ លោកស្រីបានទទួលសញ្ញាប័ត្របណ្ឌិតច្បាប់ (*honoris causa*) និងសញ្ញាប័ត្របរិញ្ញាប័ត្រផ្នែកច្បាប់ រដ្ឋប្បវេណីពីសាកលវិទ្យាល័យ College Dublin ព្រមទាំងសញ្ញាប័ត្រមេធាវីពីគណៈមេធាវី Honourable Society of King's Inns ។

*សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖*
លោក នេត្រ ភក្ត្រា
ប្រធានផ្នែកកិច្ចការសាធារណៈនិងជាអ្នកនាំពាក្យ
ទូរស័ព្ទចល័ត+៨៥៥(០)១២៨៤៨១៥៦
អ៊ីមែល៖ neth.pheaktra@eccc.gov.kh